អត្ថបទ វិចារណកថា

វ៉ុល៥, លេខ០៣, ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៣

# បដិវត្តន៍ពណ៌ ជាព្យសនកម្មអាក្រក់ សម្រាប់សន្តិភាព និងការអភិវឌ្ឍ

រស់ សយម្ភូ*

ការបះបោរ (insurrection) កាលពីឆ្នាំ២០២០ នៅវិមាន Capitol Hill នៃសហរដ្ឋអាមេរិក ត្រូវបានអាជ្ញាធរអាមេរិក អនុវត្តនីតិវិធីច្បាប់ និងចាប់ខ្លួន ចំពោះអ្នកមានទំនាក់ទំនង នៅក្នុងព្រឹត្តិការណ៍ខាងលើ។ ដោយឡែក ប្រទេសអាល្លឺម៉ង់ ក៏បានអនុវត្តនីតិវិធីច្បាប់ ក្នុងការចាប់ខ្លួនបុគ្គលមួយចំនួន ដែលត្រូវបានសង្ស័យថាបានរៀបចំការធ្វើរដ្ឋប្រហារ កាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២២ កន្លងទៅ ដូចគ្នា។ ត្រង់ចំណុចនេះ គឺបញ្ជាក់ថា មិនថា ការបះបោរ ឬ ការធ្វើរដ្ឋប្រហារ គឺសុទ្ធតែត្រូវបានចាត់ចូលជាទម្រង់មួយនៃការធ្វើបដិវត្តន៍ (Inwegen, 2011)។ ស្តែងតាម ឧទាហរណ៍ជាក់ស្តែងខាងលើ រដ្ឋ មានសិទ្ធិពេញលេញក្នុងការអនុវត្តនីតិវិធីច្បាប់ ចំពោះទម្រង់ណាមួយនៃបដិវត្តន៍ ដែលគំរាមកំហែងសន្តិសុខ និងសន្តិភាពជាតិ។ យ៉ាងណាក្តី បញ្ហានៃការអនុវត្តស្តង់ដាពីរ នៅតែបង្កជាការគំរាមកំហែង និងអរិភាពចំពោះពិភពលោក ពិសេសចំពោះប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការកសាង និងរក្សាសុខសន្តិភាព អធិបតេយ្យ និងស្វ័យភាពក្នុងការការពារខ្លួន។ ជាក់ស្តែង តាមរយៈឧទាហរណ៍ នៅប្រទេសអឺរ៉ុបខាងកើត បញ្ហាបដិវត្តន៍ពណ៌នេះ ត្រូវបានអត្ថបទរំលឹកទ្រឹស្តី (Literature Review) បានបង្ហាញថា ជាឧបករណ៍សម្រាប់បស្ចិមប្រទេសប្រើប្រាស់ដើម្បីផ្លាស់ប្តូររបបមេដឹកនាំរដ្ឋនានា ដែលពុំបម្រើផលប្រយោជន៍ខ្លួន ដោយជ្រកក្រោមស្លាកប្រជាធិបតេយ្យ។

ជាមួយនឹងការយល់ឃើញអំពីសារៈសំខាន់នៃប្រធានបទនេះ ជាពិសេសក្នុងកិច្ចការពារសន្តិភាព និងការអភិវឌ្ឍ អត្ថបទនេះ នឹងសិក្សាទៅលើ៖ (១) អ្វីជាបដិវត្តន៍ពណ៌? (២) ជាតុផ្សំសំខាន់ៗ និងដំណើរប្រព្រឹត្តទៅនៃបដិវត្តន៍ពណ៌ (៣) អ្វីជាគោលបំណងនៃបដិវត្តន៍ពណ៌? និង (៤) ភាពចលាចលដែលនឹងបង្កឡើងដោយបដិវត្តន៍ពណ៌ ដោយប្រើប្រាស់វិធីសាស្រ្តស្រាវជ្រាវ Critical Discourse Analysis ក្នុងការសិក្សាស្រាវជ្រាវ ដោយធ្វើការសិក្សា និងប្រៀបធៀបទៅលើអត្ថបទស្រាវជ្រាវរំលឹកទ្រឹស្តី ដទៃទៀត ក៏ដូចជាករណីសិក្សាអំពីបដិវត្តន៍ពណ៌ ដែលកើតមាននៅលើពិភពលោក។

## អ្វីជាបដិវត្តន៍ពណ៌?

បើពិនិត្យមើលក្នុងវចនានុក្រម សម្តេចព្រះសង្ឃរាជ **ជួន ណាត** បដិវត្តន៍ គឺមានន័យថា «ការវិលត្រឡប់, ការប្រែប្រួល, ការកែប្រែ ឬផ្លាស់ប្តូរ។» រីឯ ពណ៌ មានន័យថា «សម្បុរ, ពណ៌ស, ពណ៌ក្រហម ... »។ តាមរយៈការពន្យល់ពាក្យខាងលើ ការផ្គុំគ្នានៃពាក្យ "បដិវត្តន៍ពណ៌" អាចមានន័យថា សកម្មភាព ឬបំណងនៃការផ្លាស់ប្តូរ ការកែប្រែអ្វីមួយ ហើយការផ្លាស់ប្តូរនេះគឺប្រើប្រាស់ពណ៌ ឬកំណត់សម្គាល់នានា ដើម្បីជាអត្តសញ្ញាណ។ យ៉ាងណាមិញ ការស្រាវជ្រាវរំលឹកទ្រឹស្តី បានបង្ហាញថាពាក្យ បដិវត្តន៍ពណ៌ នេះមានការឱ្យនិយមន័យផ្សេងៗគ្នា ពិសេសទៅតាមបណ្តារដ្ឋនានា ដោយពុំមានការកំណត់និយមន័យជាសាកលនោះទេ (Polese & Beacháin,

* **លោក រស់ សយម្ភូ** ទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកច្បាប់អន្តរជាតិ ពីសាកលវិទ្យាល័យ Sussex ចក្រភពអង់គ្លេស និងជានិសិត្សថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកសន្តិសុខ, វិវាទ និងការអភិវឌ្ឍអន្តរជាតិ ពីសាកលវិទ្យាល័យ Leicester ចក្រភពអង់គ្លេស។

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

© រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

2011)។ ក៏ប៉ុន្តែ អត្ថបទស្រាវជ្រាវរំលឹកទ្រឹស្តី ក៏បានព្យាយាមកំណត់និយមន័យរួមមួយ ដោយប្រើប្រាស់វិធីសាស្ត្រសង្កេតអំពីព្រឹត្តិការណ៍ និងលំនាំនៃព្រឹត្តិការណ៍ទាំងនោះ។ ពាក្យថា បដិវត្តន៍ពណ៌ ត្រូវបានប្រើប្រាស់ជាទូទៅ សំដៅកំណត់អំពីបំណង ឬសកម្មភាពដើម្បីផ្លាស់ប្តូរបុគ្គល ឬក្រុមបុគ្គលដែលបាននិងកំពុងដឹកនាំរដ្ឋណាមួយ ដោយប្រើប្រាស់ហេតុផលនៃការលើកកម្ពស់ប្រជាធិបតេយ្យ (Kennedy, 2014)។

ការកើតចេញជាសកម្មភាពបដិវត្តន៍ពណ៌ជាទ្រង់ទ្រាយធំនោះភាគច្រើនចាប់ផ្តើមកើតឡើងកំឡុងពេលរៀបចំការបោះឆ្នោតកំឡុងពេលការបោះឆ្នោត និងក្រោយការបោះឆ្នោត ពោលគឺជាសកម្មភាពមួយដែលផ្តោតសំខាន់ ទៅលើព្រឹត្តិការណ៍បោះឆ្នោតនៃប្រទេសមួយ ដោយមានបង្កប់គោលបំណង កាត់បន្ថយ ឬកាត់ផ្តាច់ធម្មានុរូបលទ្ធផលបោះឆ្នោតនោះ ដោយឯកតោភាគីពីក្រុមមានបំណងធ្វើបដិវត្តន៍ (Stykow, 2022)។ ជាឧទាហរណ៍ការធ្វើការស្ទង់មតិក្រោយបោះឆ្នោត (Exit Poll) ដែលលទ្ធផលនៃការស្ទង់មតិនោះ នឹងមានការរៀបចំឡើងដោយបង្ហាញអំពីភាពជោគជ័យ (មិនមានការពិត) នៃក្រុមដែលមាននិន្នាការប្តូររបបដឹកនាំបច្ចុប្បន្ន ឬក្រុមបដិវត្តន៍នេះ ហើយគេនឹងប្រើប្រាស់លទ្ធផលនៃការស្ទង់មតិ (ប្រើប្រាស់ដោយឯកតោភាគី) ដើម្បីបំភ័ន្តអ្នកគាំទ្រខ្លួន និងអ្នកគាំទ្រការធ្វើបដិវត្តន៍ថាលទ្ធផលបោះឆ្នោតមានភាពមិនប្រក្រតី (បំភ្លៃថាខ្លួនបានឈ្នះរួចហើយ) ដូច្នេះទោះជាមានការបង្ហាញលទ្ធផលជាផ្លូវការ ក៏ក្រុមនេះនៅតែមិនព្រមទទួលយក និងបន្តប្រឆាំងតាមបែបប្រមូលផ្តុំធ្វើបាតុកម្ម និងប្រើប្រាស់សន្តិវិធី ជាលេស (Lane, 2009; Beissinger, 2009)។ សូមបញ្ជាក់ថា ទោះបីជាមានការបង្ហាញការផ្សារភ្ជាប់នឹងព្រឹត្តិការណ៍បោះឆ្នោតដូចបញ្ជាក់ខាងលើក៏ពិតមែន ប៉ុន្តែការរៀបចំក្រុម និងការពង្រីកពង្រឹងបណ្តាញរបស់ក្រុមបដិវត្តន៍ប្រភេទនេះ គឺត្រូវបានត្រៀមទុកជាយូរមកហើយ និងបានតែងតែធ្វើការចាក់ឆ្កឹះបញ្ហាសង្គមដូចជាបញ្ហាបរិស្ថាន បញ្ហាសិទ្ធិមនុស្ស ជាដើម ក្នុងគោលដៅសន្សំកម្លាំង ដើម្បីវគ្គផ្តាច់ព្រ័ត្រ (Brychkov & Nikonorov, 2018) ដែលនឹងបន្តបកស្រាយបន្ថែមនៅក្នុងផ្នែកបន្ទាប់នេះ។

បដិវត្តន៍ពណ៌ ជាបដិវត្តន៍មួយប្រភេទ ដែលជ្រើសយកប្រជាធិបតេយ្យ ជាលេសដើម្បីធ្វើសកម្មភាព និងមិនមានការផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងនយោបាយ ឬសេដ្ឋកិច្ចប្រទេសជាដុំកំភួននោះទេ ប៉ុន្តែជាគោលដៅ ដើម្បីគ្រប់គ្រងអំណាចប៉ុណ្ណោះ (Lane, 2009)។ បដិវត្តន៍ពណ៌ មានភាពខុសប្លែកពីបដិវត្តន៍បែបប្រពៃណី ត្រង់ថា បដិវត្តន៍បែបប្រពៃណី អាចជាទម្រង់នៃការផ្លាស់ប្តូររបបនយោបាយទាំងស្រុង ពីសាធារណរដ្ឋ មករាជានិយម ឬផ្លាស់ប្តូររចនាសម្ព័ន្ធដឹកនាំប្រទេស ដូចជា ការកែប្រែប្រព័ន្ធសេដ្ឋកិច្ចពាណិជ្ជកម្មទីផ្សារបែបផែនការទៅជាសេរីជាដើម (Lane, 2009)។ និយាយមួយបែបទៀត បដិវត្តន៍ពណ៌ គឺជាវិធីមួយដើម្បីធ្វើរដ្ឋប្រហារ ព្រោះគ្រាន់តែមានបំណងផ្លាស់ប្តូរក្បាលម៉ាស៊ីនដឹកនាំ ដើម្បីឱបក្រសោបអំណាចដោយមេដឹកនាំបាតុករ តាមរយៈការខ្ចីដៃពីកម្លាំងមហាជន ពិសេសយុវជន មកប្រើប្រាស់ (Манойло , 2014; Lane, 2009)។

សូមបញ្ជាក់ផងដែរ បដិវត្តន៍ពណ៌ គឺជាឧបរណ៍ប្រើប្រាស់ដើម្បីផ្លាស់ប្តូររបបដឹកនាំ ពិសេសនៅបណ្តាប្រទេសអឺរ៉ុបខាងកើត ដែលភាគច្រើនជារដ្ឋដែលធ្លាប់ស្ថិតក្រោមសហភាពសូវៀត មានភូមិសាស្ត្រជាចំណុចសំខាន់ក្នុងការប្រជែងភូមិ-សាស្ត្រនយោបាយដើម្បីឥទ្ធិពលប្រជាធិបតេយ្យ ដែលជាឧបករណ៍របស់បស្ចិមលោក (Zhang & Fahmy, 2009)។ រដ្ឋបស្ចិមលោកមួយចំនួន បានធ្វើការផ្លាស់ប្តូររបបដឹកនាំនៅបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ មិនមែនត្រឹមតែការចូលរួមក្នុងដំណើរការនៃការបញ្ឆេះបដិវត្តន៍ពណ៌នោះទេ តែក្នុងករណីមួយចំនួនទៀតគឺប្រើប្រាស់ឃោជាសម្លាប់មេដឹកនាំរបប ក្នុងប្រទេសកំពុងអភិវឌ្ឍន៍នានា ដោយគឃ្លើន ជាន់ឈ្លីច្បាប់អន្តរជាតិ ថែមទៀតផង ដែលទាំងអស់នេះគឺសម្រាប់តែប្រយោជន៍គោលនយោបាយការបរទេសខ្លួន ប្រយោជន៍ភូមិ-សាស្ត្រនយោបាយខ្លួន ប្រយោជន៍ពីការប្រមូលធនធានធម្មជាតិ

ដូចជា ប្រេង ឬរ៉ែកម្រនានា ពិសេសដើម្បីរក្សាអនុត្តរភាពរបស់ខ្លួនក្នុងពិភពលោក ដោយប្រើប្រាស់ប្រជាធិបតេយ្យជាចំណាប់ខ្មាំង (Mirza & Nayab, 2020)។

## ធាតុផ្សំសំខាន់ៗ និងដំណើរប្រព្រឹត្តទៅនៃបដិវត្តន៍ពណ៌

អត្ថបទស្រាវជ្រាវរំលឹកទ្រឹស្តីនិពន្ធដោយ Valery Solovei និង Ieva Bērziņa បានធ្វើការស្រាវជ្រាវលើដំណើរការប្រព្រឹត្តទៅនៃបដិវត្តន៍ពណ៌កន្លងមក។ អ្នកនិពន្ធទាំងពីរ បានបង្ហាញនូវ លទ្ធផលស្រាវជ្រាវប្រហាក់ប្រហែលគ្នា ស្តីពី ធាតុផ្សំសំខាន់ៗ ចំនួនប្រាំមួយ នៃលំនាំផែនការរៀបចំបដិវត្តន៍ពណ៌ ដែលមានដូចជា៖

> (១) ការប្រើប្រាស់បញ្ហាដំណើរប្រព្រឹត្តទៅនៃការបោះឆ្នោត និងបញ្ហាសង្គម (២) ការជួយជ្រោមជ្រែងដោយតួអង្គខាងក្រៅ (៣) ការចោទប្រកាន់បុគ្គលកាន់អំណាចអំពីអត្តាធិបតេយ្យ (autocracy) និងអះអាងថាក្រុមខ្លួនគឺពង្រឹងលទ្ធិប្រជាធិបតេយ្យ (៤) ការចូលរួមពីប្រជាជន ពីយុវជនច្រើន និងឥស្សរជនមានឥទ្ធិពល (៥) ការបែកបាក់នៃក្រុមឥស្សរជនមានឥទ្ធិពលកំពុងកាន់អំណាច និង (៦) ការប្រើប្រាស់យុទ្ធសាស្ត្របែបសន្តិវិធី។ (Solovei, 2015; Bērziņa, 2019)

អត្ថបទស្រាវជ្រាវរំលឹកទ្រឹស្តី ក៏បង្ហាញអំពីជំហានសំខាន់ៗ បួនសម្រាប់ដំណើរប្រព្រឹត្តទៅនៃបដិវត្តន៍ពណ៌ ដើម្បីកៀរគរអ្នកគាំទ្រចូលរួម ដែលតាមទ្រឹស្តីរបស់ Gene Sharp មានដូចជា៖

> (១) កំណត់អត្តសញ្ញាណ ហើយត្រូវបណ្តុះបណ្តាល ពង្រឹងឆន្ទៈ ទំនុកចិត្ត និងជំនាញតស៊ូរបស់បុគ្គលដែលជួបបញ្ហាសង្គម (២) បង្កើត និងពង្រឹងក្រុមសង្គមឯករាជ្យ និងអង្គការដែលទទួលបន្ទុកលើបុគ្គលដែលជួបបញ្ហាសង្គម (៣) ពង្រឹងពង្រីកឥទ្ធិពលនៃកម្លាំងផ្ទៃក្នុង និង (៤) បង្កើតផែនការយុទ្ធសាស្ត្រឈ្លាសវៃមួយ និងត្រូវមានអ្នកអនុវត្តប្រកបដោយជំនាញ ជ្រកក្រោមបុព្វហេតុសេរីភាព។
>
> ទិសដៅរយៈពេលខ្លី៖ ធ្វើសកម្មភាពលើបញ្ហាសង្គម។
>
> ទិសដៅរយៈពេលមធ្យម៖ បង្កើតវប្បធម៌ ស្ថាប័ន និងបណ្តាញ។
>
> ទិសដៅចុងក្រោយ៖ ប្រើប្រាស់បណ្តាញនោះនៅពេលសមស្រប ដើម្បីប្រឆាំងនឹងរដ្ឋអធិបតេយ្យនោះ។ (Nikmoeen, 2017)

## អ្វីជាគោលបំណងនៃបដិវត្តន៍ពណ៌?

នៅពេលលឺពាក្យ បដិវត្តន៍ពណ៌ អ្វីដែលអ្នកសិក្សាស្រាវជ្រាវ ឬសាធារណជន អាចនឹកដល់នោះគឺ សកម្មភាព ឬបំណងដើម្បីផ្តួលរំលំរបបណាមួយ ដោយប្រើហេតុផលប្រជាធិបតេយ្យ។ ពណ៌ ឬការកំណត់អត្តសញ្ញាណគឺមានសារៈសំខាន់ ដើម្បីផ្តល់ការងាយស្រួលដល់ការបង្ហាញអំពីចំណុចទាក់ទាញ ភាពសម្បើម ឬសក្តានុពល ដើម្បីផ្សព្វផ្សាយ និងដើម្បីបំភ្លែកម្លាំងរបស់អ្នកដឹកនាំរបបនាពេលបច្ចុប្បន្ន (Polese & Beacháin, 2011) ដូចជា បដិវត្តពណ៌ទឹកក្រូចនៅអ៊ុយក្រែន ឬ បដិវត្តន៍ផ្កាកូឡាបនៅ ហ្សកហ្ស៊ី (Lane, 2008)។ ជាមួយគ្នានេះ ពិតហើយពាក្យ បដិវត្តពណ៌ ត្រូវបានប្រើប្រាស់ជាហូរហែនៅក្នុងសង្គមកម្ពុជា ក៏ប៉ុន្តែអត្ថបទស្រាវជ្រាវនេះ មានបំណងផ្តល់ជាធាតុចូល សម្រាប់សាធារណជន អ្នកសិក្សាស្រាវជ្រាវ ដោយលើកយកការសិក្សាទៅលើអត្ថបទស្រាវជ្រាវរំលឹកទ្រឹស្តី និងការបញ្ជាក់អំពីអវិភាពដែលពុំអាចមើលរំលង។ បដិវត្តន៍ពណ៌ពុំមែនជាគោលដៅទេ តែគ្រាន់តែជាគឺជាឧបករណ៍ ឬមធ្យោបាយ (it is not an end but a mean)។ អ្វីដែលសំខាន់ ហើយគ្រោះថ្នាក់នោះគឺ អ្នកចូលរួម ឬមានបំណងចូលរួម មិនបានយល់ច្បាស់ អំពីបំណងពិតប្រាកដ និងទិសដៅអនាគតគ្រប់ជ្រុងជ្រោយនៃមេដឹកនាំបដិវត្តន៍នេះ ដែលបំណងពិតប្រាកដរបស់ពួកគេគឺស្មោះស្ម័គ្រចំពោះអំណាច និងប៉ុនប៉ងរដ្ឋប្រហារប៉ុណ្ណោះ។

មកត្រឹមចំណុចនេះ ថ្វីត្បិតតែ បដិវត្តន៍ពណ៌ មានធាតុផ្សំសន្តិវិធីនៅក្នុងនោះក៏ពិតមែន ក៏ប៉ុន្តែសកម្មភាពនេះ អាចក្លាយជាសង្គ្រាម ឬជាការផ្ទុះអាវុធគ្រប់ពេល (Манойло, 2014)។ ដូចបានជម្រាបខាងលើ បដិវត្តន៍ពណ៌ ពុំមែនកើតឡើងដោយអវត្តមានការជ្រៀតជ្រែកពីតួអង្គខាងក្រៅនោះទេ។ សំណួរសួរថា តើផ្អែកលើមូលដ្ឋានអ្វីដែលពួកគេសម្រេចចិត្តលូកដៃ? នោះគឺប្រជាធិបតេយ្យ ដែលជាឧបករណ៍នយោបាយការបរទេស

សម្រាប់បស្ចិមប្រទេសមួយចំនួន ប្រើប្រាស់ដើម្បីបម្រើឱ្យប្រយោជន៍ខ្លួន (Baev, 2011)។ ប្រជាធិបតេយ្យ គឺតែងត្រូវបានប្រើប្រាស់ជាឧបករណ៍សំខាន់មួយ ក្នុងការបញ្ជេះឱ្យមានបដិវត្តន៍ពណ៌ ហើយដើម្បីអុចអាលឱ្យក្លាយជាសង្គ្រាម ដូចបានបង្ហាញនៅក្នុងនិយមន័យ ហើយ ប្រជាធិបតេយ្យ គ្រាន់តែជាចំណាប់ខ្មាំងតែប៉ុណ្ណោះ។ ជាក់ស្ដែង ប្រជាធិបតេយ្យមិនសំខាន់ដូចតម្លៃនៃធនធានធម្មជាតិប្រេងកាត សុវត្ថិភាពនៃការវិនិយោគ និងផលប្រយោជន៍ផ្ទាល់ខ្លួន សម្រាប់បស្ចិមប្រទេសមួយចំនួននោះទេ។ ជាឧទាហរណ៍កន្លងមក ទោះប្រទេសខ្លះមានបញ្ហាចម្រូងចម្រាសនៃសិទ្ធិមនុស្ស និងប្រជាធិបតេយ្យក៏ដោយ ក៏បស្ចិមប្រទេសនៅតែអាចរក្សាកិច្ចសហប្រតិបត្តិការល្អ (Beacháin & Polese, 2010)។ ត្រង់ចំណុចនេះ កត្តាភូមិសាស្ត្រនយោបាយ ក៏ជាកាតាលីករមួយជំរុញឱ្យមាន បដិវត្តន៍ពណ៌ ដែលអាចនឹងកើតមានចំពោះប្រមុខដឹកនាំ ដែលពុំបម្រើឱ្យផលប្រយោជន៍ភូមិសាស្ត្រនយោបាយប្រទេសមានអំណាច (Simons, 2021)។ ការណ៍នេះហើយ ទើបការលូកដៃនៃតួអង្គក្រៅប្រទេស មានសារៈសំខាន់ និងជាធាតុផ្សំពុំអាចរំលងបាន។ ទាំងនេះគឺបានបង្ហាញគ្រប់គ្រាន់ថា ទោះធ្វើតាមសន្តិវិធីក៏ដោយ ផែនការយុទ្ធសាស្ត្រនៃបដិវត្តន៍ពណ៌ មានភាពស្មុគស្មាញ និងគ្រោះថ្នាក់យ៉ាងខ្លាំងដល់សន្តិភាព និងការអភិវឌ្ឍ ហើយជាចុងក្រោយគឺដើម្បីបម្រើប្រយោជន៍បរទេសតែប៉ុណ្ណោះ។ សូមរំលឹកឡើងវិញថា បដិវត្តន៍ពណ៌ ធ្វើឡើងក្នុងរូបភាពធំដុំកំឡុងពេលនៃព្រឹត្តិការណ៍បោះឆ្នោត ដោយអាចចាប់ផ្ដើមសកម្មភាពពីការចោទប្រកាន់ដំណើរការនៃការបោះឆ្នោត ហើយនិងបន្តគួបផ្សំជាមួយបញ្ហាប្រជាធិបតេយ្យ និងសិទ្ធិមនុស្សដទៃទៀត ដែលក្រុមនេះ បានសន្សំមកជាបណ្ដាញជាយូរ។ ការធ្វើបែបនេះពុំមែនអាចកើតឡើង ដោយការស្រមើស្រមៃនោះទេ តែតម្រូវឱ្យមានការបណ្ដុះបណ្ដាល រៀនសូត្រ បង្កើតបណ្ដាញ បង្កើតនូវប្រព័ន្ធគុណតម្លៃប្រជាធិបតេយ្យ រហូតដល់ការត្រៀមរៀបចំបំពាក់បំប៉ន និងហ្វឹកហ្វឺនអ្នកចូលរួមឱ្យប្រើប្រាស់អាវុធពីតួអង្គខាងក្រៅទៀតផង។ ប្រទេសដែលតែងតែមានភាពសកម្មក្នុងការគាំពារប្រជាធិបតេយ្យ ទទួលផលចំណេញច្រើនជាងគេ ព្រោះជាអំណាចទន់មួយ សម្រាប់ខ្លួន ក្នុងការប្រើប្រាស់ប្រជាធិតេយ្យ និងបដិវត្តន៍ពណ៌ ជាឈ្នាន់ដើម្បីជាប្រយោជន៍ (Solovei, 2015)។ ដែលថាជាអំណាចទន់នោះ ព្រោះរដ្ឋបស្ចិមលោកមួយចំនួន ប្រើប្រាស់មនោគមវិជ្ជាប្រជាធិបតេយ្យ សិទ្ធិមនុស្ស ក៏ដូចជាអំណាចហិរញ្ញវត្ថុ ជាឧបករណ៍ដើម្បីដាក់បេសកម្ម និងគោលដៅសម្រាប់ក្រុមធ្វើបដិវត្តន៍។ ឧទាហរណ៍ ការជួយឧបត្ថម្ភរាប់សិបលានដុល្លារដល់ដល់ក្រុមសង្គមស៊ីវិលឯករាជ្យ អង្គការសង្គមស៊ីវិល ក្នុងនោះករណីអ៊ុយក្រែនមានរហូតដល់ពាន់លានដុល្លារ ការបណ្ដុះបណ្ដាលរបៀបធ្វើបដិវត្តន៍ ការជួយជ្រោមជ្រែងដោយប្រព័ន្ធផ្សព្វផ្សាយបរទេស ការផ្ដល់ជំនួយថវិកាដល់គណបក្សនយោបាយប្រឆាំង ការផ្គត់ផ្គង់សព្វាវុធ និងបណ្ដុះបណ្ដាលយោធា ដើម្បីបង្កើតវប្បធម៌ស្ថាប័ន និងបណ្ដាញបដិវត្តន៍ពណ៌នេះជាដើម (Dzarasov & Gritsenko, 2020; Antwerp & Brown, 2018)។

## ភាពចលាចលបង្កឡើងដោយបដិវត្តន៍ពណ៌

ដើម្បីដឹងថា បដិវត្តន៍ពណ៌ នឹងបង្កជាចលាចល ឬបន្សល់ទុកនូវបញ្ហាបែបណានោះ គេត្រូវស្វែងយល់ថា ហេតុអ្វីបដិវត្តន៍ពណ៌ គឺជាឧបករណ៍ ហើយមិនមែនជាគោលដៅ? ពីព្រោះ មិនមានអ្នកណាអាចកំណត់បានថា អ្នកណាជាអ្នកកំណត់ស្តង់ដាប្រជាធិបតេយ្យ, មិនមានអ្នកណា អាចអះអាងបានថា ក្រុមបដិវត្តន៍ដែលទទួលជំនួយឧបត្ថម្ភជ្រោមជ្រែងពីតួអង្គខាងក្រៅអាចធានាបានការមិនប៉ះទង្គិចអាវុធ, មិនមានអ្នកណាអាចធានាបានថា មេដឹកនាំបដិវត្តន៍ មិនរត់ចោល ពេលមានបញ្ហា ឬបោះបង់លែងខ្វល់ខ្វាយពីប្រជាជន និងអ្នកគាំទ្រខ្លួនបន្ទាប់ពីទទួលបានអំណាច, មិនមានអ្នកណាអាចអះអាងបានថា ពេលដែលទទួលបានអំណាចហើយ ក្រុមសម្ព័ន្ធរវាងឥស្សរជនចាស់ និងថ្មី និងបន្តធ្វើការជាមួយគ្នាបានទេ។

ដូច្នេះតើគេធ្វើបដិវត្តន៍ពណ៌ដើម្បីអ្វី? គ្មានអ្នកណាអាចដឹងពីអនាគតបានទេ "ការសន្យា មិនមែនជាការពិត"។ អ្វីដែលច្បាស់លាស់នោះគឺ តាមរយៈបទពិសោធន៍ករណីសិក្សាកន្លងមក អ្នករៀបចំបដិវត្តន៍ពណ៌ ពុំអាចធ្វើការតែឯកឯងបាន និងមិនមានធនធានគ្រប់គ្រាន់ក្នុងការរៀបចំនោះទេ ពិសេសការរៀបចំការធ្វើបែបនេះតម្រូវឱ្យមានការគិតគូរល្អិតល្អន់ និងត្រូវរៀបចំជាផែនការយុទ្ធសាស្ត្រទៅតាមដំណាក់កាលដោយសារតែភាពស្មុគស្មាញ ដែលបង្ហាញពីកត្តាសត្យានុម័តនៃការចូលរួមរបស់ តួអង្គខាងក្រៅ (Kozłowski, 2016)។ លើសពីនេះ រយៈពេលច្រើនឆ្នាំបន្ទាប់ពីបដិវត្តន៍ពណ៌កើតឡើង នៅក្នុងបណ្តាប្រទេសអឺរ៉ុបខាងកើត អ្វីដែលគេអាចមើលច្បាស់ចេញពីបដិវត្តន៍ពណ៌នោះ គឺអស្ថិរភាព ភាពចលាចល អនាធិបតេយ្យ និងការដើរថយក្រោយ។ ករណីសិក្សានៅ ហ្សកហ្ស៊ី នៅឆ្នាំ២០០៣ បានបង្ហាញថា អ្នកផ្តើមគំនិតធ្វើបដិវត្តន៍ពណ៌នៅពេលទទួលបានអំណាច មិនអាចរក្សានូវសន្យា និងការធានាខ្លួនបាននោះទេ ហើយផ្ទុយទៅវិញបានរំលោភអំណាច រំលោភបំពានសិទ្ធិមនុស្ស និងប្រជាធិបតេយ្យទៅវិញ។ ការណ៍នេះបានបន្តរុញច្រាន ហ្សកហ្ស៊ី ចូលទៅក្នុងសង្គ្រាមនៅឆ្នាំ២០០៨ ផងដែរ (Kalandadze & Orenstein, 2009; Kozłowski, 2016) ។ ស្រដៀងគ្នានេះ បដិវត្តន៍ពណ៌ទឹកក្រូច នៅអ៊ុយក្រែនឆ្នាំ២០០៤ ពុំបានបង្ហាញពីលទ្ធផល និងលទ្ធភាពក្នុងការធ្វើឱ្យប្រសើរឡើងតាមការសន្យានោះទេ។ ផ្ទុយទៅវិញ អ៊ុយក្រែនត្រូវបានទាញថយក្រោយពីវិឌ្ឍនភាពសង្គម និងមានការគំរាមគំហែងជាបន្តបន្ទាប់ពីបដិវត្តន៍ពណ៌ ដែលអស្ថិរភាពនេះបានរួមចំណែកដល់ផ្ទុះឡើងជាសង្គ្រាម ដោយមូលហេតុភូមិសាស្ត្រនយោបាយ (Lane, 2009; 2008)។

នៅកៀហ្ស៊ីស៊ីស្ថាន ដែលមានបដិវត្តន៍ផ្កាទូលីបឆ្នាំ២០០៥ ក៏ពុំមានការប្រសើរឡើងនៃស្ថានការណ៍ប្រទេស ជាងពេលមុនបដិវត្តន៍ពណ៌ដែរ ពោលគឺមានតែកើនឡើងនៃបញ្ហាសង្គមទៅវិញ (Lane, 2009)។

មួយវិញទៀត បដិវត្តន៍ពណ៌ ច្បាស់ណាស់នឹងធ្វើឱ្យស្ថានភាពសេដ្ឋកិច្ច និងពាណិជ្ជកម្ម ពិសេសដោយវិនិយោគិនបរទេស ដកសេចក្តីទុកចិត្ត ហើយក្នុងករណីនេះ នឹងក្លាយជាកត្តាដ៏សំខាន់មួយដើម្បីពិចារណាលើលទ្ធផល បន្ទាប់ពីបដិវត្តន៍ពណ៌ (Solovei, 2015)។ លើសពីនេះ បន្ទាប់ពី បដិវត្តន៍ពណ៌ ក្រុមសម្ព័ន្ធនៃឥស្សរជនរបបចាស់ និងថ្មី នឹងអាចមានការបែកបាក់គ្នា ហើយនឹងបង្កជាអរិភាពដល់សេដ្ឋកិច្ច និងសណ្តាប់ធ្នាប់សង្គម ព្រមទាំងបន្តជាសង្គ្រាមស៊ីវិល កើតចេញពីសម្ព័ន្ធរបស់ក្រុមខ្លួនទៀតផង (Way, 2008; Zhou & Tang, 2021)។ គួរបញ្ជាក់ផងដែរថា នៅពេលវិបត្តិទាំងនេះកើតឡើង ជំនួយបរទេសកាន់តែសំខាន់សម្រាប់ក្រុមនីមួយៗ ហើយវានឹងក្លាយជាឱកាសក្នុងការពង្រីកអំណាចទន់ របស់បរទេស នៅក្នុងរដ្ឋនោះ (Lane, 2009)។ ដូច្នេះហើយទើបការរក្សាសុខសន្តិភាព អធិបតេយ្យភាព និងតម្រូវការក្នុងការប្រឆាំងឥតងាករេចំពោះបដិវត្តន៍ពណ៌ គឺមានភាពចាំបាច់ណាស់។

សរុបសេចក្តីមក ប្រជាធិបតេយ្យ ត្រូវបានប្រើប្រាស់ជាលេសដើម្បីកំណត់ក្តីសម្រេ និងដើម្បីកៀរគរអ្នកចូលរួម។ ប្រជាធិប-តេយ្យ និងបដិវត្តន៍ពណ៌ គឺជាឧបករណ៍នយោបាយការបរទេសរបស់បស្ចិមប្រទេសមួយចំនួន ដើម្បីប្រយោជន៍នយោបាយ សន្តិសុខ និងសេដ្ឋកិច្ចផ្ទាល់ខ្លួន។ មួយវិញទៀត ការសន្យា ឬអះអាងថាជាសន្តិវិធីនេះ គ្រាន់តែជារូបភាព ដើម្បីទាក់ទាញ និងបំភ័ន្តទឹកចិត្តសាធារណជន ហើយការចូលរួមនេះទៀតសោត ត្រូវការបង្ហាញនូវភាពសម្បើម ជាចំនួនក្តី ឬតាមរយៈការប្រើប្រាស់អត្តសញ្ញាណដូចជាពណ៌ ឬផ្កា ជាដើម។ ទន្ទឹមនឹងនេះ ក្រុមបដិវត្តន៍នេះ អាចមានការត្រៀមរៀបចំហ្វឹកហ្វាត់សព្វាវុធដោយលាក់លៀម ឬប្រកាសឱ្យមានការចូលរួមបង្វែរកាណុងអាវុធទៅរបបដឹកនាំរួចទៅហើយ ដែលការណ៍នេះហើយជាការលាក់ពុតនៃវិធីសាស្ត្រនៃបដិវត្តន៍ពណ៌។ ជាចុងក្រោយ បដិវត្តន៍ពណ៌ មានភាពច្បាស់លាស់តែមួយគត់គឺ "បដិវត្តន៍ពណ៌ ជាឃាតករសម្លាប់សន្តិភាព និងការអភិវឌ្ឍ"។

## ឯកសារយោង


Antwerp, A. C. V, & Brown, N. J. (2018). The Electoral Model Without Elections? The Arab Uprisings of 2011 and the Color Revolutions in Comparative Perspective. *Demokratizatsiya*, *26*(2), 195–226.

Baev, P. K. (2011). A Matrix for Post-Soviet ' Color Revolutions ': Exorcising the Devil from the Details. *International Area Studies Review*, *14*(2), 3–22. https://doi.org/10.1177/223386591101400201

Beacháin, D. Ó., & Polese, A. (2010). What Happened to the Colour Revolutions ? Authoritarian Responses from Former Soviet Spaces. *Journal of International and Area Studies*, *17*(2), 31–51.

Beissinger, M. R. (2009). An Interrelated Wave Debating the Color Revolutions an interrelated wave. *Journal of Democracy*, *20*(1), 74–77. https://doi.org/10.1353/jod.0.0048

Bērziņa, I. (2019). Weaponization of "Colour Revolutions." *Journal of Political Marketing*, *18*(4), 330–343. https://doi.org/10.1080/15377857.2019.1678905

Brychkov, A. S., & Nikonorov, G. A. (2018). Color Revolutions in Russia: Possibility and Reality. *Russia's Journal of the Academy of Military Science*, 1–7. https://community.apan.org/wg/tradoc-g2/fmso/m/fmso-monographs/225467

Dzarasov, R., & Gritsenko, V. (2020). Colours of a revolution . Post-communist society , global capitalism and the Ukraine crisis. *Third World Quarterly*, *41*(0), 1289–1305. https://doi.org/10.1080/01436597.2020.1732202

Inwegen, P. V. (2011). Understanding Revolution. In *Understanding Revolution* (pp. 1–20).

Kalandadze, K., & Orenstein, M. A. (2009). Electoral Protests and Democratization. *Comparative Political Studies*, *42*(11), 1403–1425.

Kennedy, R. (2014). Fading Colours ? A Synthetic Comparative Case Study of the Impact of " Colour Revolutions ". *Comparative Politics*, *46*(3), 273–292.

Kozłowski, K. (2016). The Colour Revolutions in the Post-Soviet Space : Illusion and Reality of the Post-Soviet Civil Disobedience. *Studia z Polityki Publicznej*, *4*(12), 135–151.

Lane, D. (2008). The Orange Revolution: 'People's Revolution' or Revolutionary Coup? *British Journal of Politics and International Relations*, *10*(4), 525–549. https://doi.org/10.1080/13523270902860295

Lane, D. (2009). ' Coloured Revolution ' as a Political Phenomenon. *Journal of Communist Studies and Transition Politics*, *25*(2–3), 1133–1135. https://doi.org/10.1080/13523270902860295

Mirza, M. N., & Nayab, A. (2020). US Policy of Regime Change: Interplay of Systemic Constraints, Leaders' Perceptions, and Domestic Pressures. *Global Social Sciences Review*, *V*(III), 307–316. https://doi.org/10.31703/gssr.2020(v-iii).32

Nikmoeen, J. (2017). Review of Color Revolution. *International Journal of New Technology and Research*, *3*(8), 13–15.

Polese, A., & Beacháin, Ó. D. (2011). The Color Revolution Virus and Authoritarian Antidotes: Political Protest and Regime Counterattacks in Post-Communist Spaces. *Demokratizatsiya*, *19*(2), 111–132.

Simons, G. (2021). Postprint Geopolitical Regionalisms Resulting From US-Led GWOT , Colour Foreign Policy. *Journal of Political Science*, *9*(2), 263–284.

Solovei, V. (2015). Color revolutions and Russia. In *Democracy in a Russian Mirror* (Issue April, pp. 78–94). https://doi.org/10.1017/CBO9781107282070.005

Stykow, P. (2022). Making Sense of a Surprise : Perspectives on the 2020 " Belarusian Revolution ." *Nationalities Papers (2022),* 1–20. https://doi.org/10.1017/nps.2022.93

Way, L. (2008). The Real Causes of the Color Revolutions. *Journal of Democracy*, *19*(3), 55–69. https://doi.org/10.1353/jod.0.0010

Zhang, J., & Fahmy, S. (2009). Colored Revolutions in Colored Lenses : A Comparative Analysis of U . S . and Russian Press Coverage of Political Movements in Ukraine , Belarus , and Uzbekistan University of Texas at San Antonio University of Arizona. *International Journal of Communication*, *3*, 517–539.

Zhou, Y., & Tang, S. (2021). The Rupture of Revolutionary Coalition After Color Revolution : The Semi-Negative Case Comparison of Egypt and Tunisia The Rupture of Revolutionary Coalition After Color Revolution : The Semi-Negative Case Comparison. *Asian Journal of Middle Eastern and Islamic Studies*, *15*(3), 344–359. https://doi.org/10.1080/25765949.2021.1984068

Манойло, А. В. (2014). Color revolutions: theory and practice of modern political regimes dismantling. *КОНФЛИКТОЛОГИЯ*, *1*(1), 40–47. https://doi.org/10.7256/.2014.1.13519



Cambodia Development Center

Cambodia Development Center (@cd.centerkh)

Cambodia Development Center

Cambodia Development Center (t.me/cdcenterkh)

The Kampus Building, Unit 1D, Street 93, Sangkat Tonle Bassac, Khan Chamkarmon

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center